D306/15

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 19-Aug-2016, 10:02
CMS/CFO: Ly Bunloung

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខៈ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០១៦

ភាសា ៖ អង់គ្លេស [ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ **សាធារណៈ**

## សេចក្តីជូនដំណឹងអំពីការបន្ថែមចំនួនកំណត់នៃទំព័រដើម្បីឆ្លើយតបសារណារបស់*អ្នកដែលមិនមែនជាភាគី*

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា៖**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី**
**មាស មុត**
អាង ឧត្តម
Michael G. KARNAVAS

**មេធាវីតំណាង**
**ដើមបណ្តឹងរដ្ឋប្បវេណី៖**
ហុង គីមសួន
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ
Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Bernabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES
ជេត វណ្ណលី
ឡោ ជុនធី
Yiqiang LIU
ស៊ិន សុវ៉ន
Beini YE

## I- ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ យើងបានអញ្ជើញ *អ្នកដែលមិនមែនជាភាគី* និងពីភាគីក្នុងសំណុំរឿង ០០៣ និង ០០៤ ដាក់សារណា ស្ដីពីថាតើក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិជាធរមាន ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ការវាយប្រហារពីសំណាក់រដ្ឋ ឬអង្គការចាត់តាំងណាមួយទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន អាចជាការវាយប្រហារសំដៅទៅលើប្រជាជនស៊ីវិលសម្រាប់គោលបំណងនៃមាត្រា៥នៃច្បាប់ អ.វ.ត.ក ដែរឬយ៉ាងណា។ យើងក៏បានជូនដំណឹងទៅភាគីថាពួកគាត់អាចដាក់ចម្លើយតបរួមទៅនឹងសារណារបស់*អ្នកដែលមិនមែនជាភាគី* ក្នុងអំឡុងរយៈ ពេល ១៥ ថ្ងៃគិតចាប់ពីថ្ងៃជូនដំណឹង ហើយថាចំនួនកំណត់នៃទំព័រសម្រាប់ចម្លើយតបរួមបញ្ចូលគ្នាទាំងនេះ គឺបីពាន់ពាក្យដោយគិតទាំងជើងទំព័រ ("សេចក្ដីអំពាវនាវឱ្យដាក់សារណា")[1]។

2. មកទល់ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ សារណាចំនួនដប់មួយត្រូវបានដាក់ដោយអ្នកស្រាវជ្រាវ និងស្ថាប័នផ្សេងៗ តបសេចក្ដីអំពាវនាវរបស់យើងសុំឱ្យដាក់សារណា។

3. នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦ មេធាវីការពារក្ដី មាស មុត ក្នុងសំណុំរឿង ០០៣ បានស្នើសុំការអនុញ្ញាតដើម្បីដាក់ចម្លើយតបរួមមួយដែលមានចំនួន ១៥ ទំព័រ ដោយសំអាងថាពួកគាត់ពុំអាចឆ្លើយតបគ្រប់គ្រាន់ទៅនឹងសារណាចំនួនដប់មួយរបស់*អ្នកដែលមិនមែនជាភាគី* ក្នុងចំនួនបីពាន់ពាក្យបានឡើយ[2]។

## II. ពិភាក្សា

4. ដោយពិចារណាអំពីចំនួនដ៏ច្រើននៃសារណារបស់ *អ្នកដែលមិនមែនជាភាគី* ដែលបានទទួល យើងយល់ឃើញថាជាការសមស្របដើម្បីបន្ថែមចំនួនកំណត់នៃទំព័រសម្រាប់ចម្លើយតបរួម ដូចដែលបានស្នើសុំដោយមេធាវីការពារក្ដី មាស មុត។

5. ដីកាសម្រេចនេះត្រូវបានដាក់ជាភាសាអង់គ្លេស ដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

---

[1] សំណុំរឿង ០០៣-D191, *សេចក្ដីអំពាវនាវសុំឱ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី*, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦។ សំណុំរឿង ០០៤-D306, *សេចក្ដីអំពាវនាវសុំឱ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី*, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦។

[2] សំណុំរឿង ០០៣-D191/14, *សំណើរបស់មាស មុត សុំអនុញ្ញាតដាក់ចម្លើយរួមចំនួន ១៥ ទំព័រ តបទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគីលើបញ្ហាដែលថាតើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬអង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនផ្ទាល់អាចជាការវាយប្រហារដែលសំដៅទៅលើប្រជាជនស៊ីវិល ឬយ៉ាងណា*, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦។

**តាមសម្អាងហេតុខាងលើ យើង៖**

6. **កែប្រែ** ចំនួនកំណត់បីពាន់ពាក្យសម្រាប់ចម្លើយតបរួមដែលត្រូវបានកំណត់ក្នុងសេចក្តីអំពាវនាវសុំឲ្យដាក់សារណា។

7. **ជូនដំណឹង** ទៅភាគីថាចំនួនកំណត់ថ្មីនៃទំព័រសម្រាប់ចម្លើយតបរួម គឺដប់ប្រាំទំព័រ និង

8. **កត់សម្គាល់** ថាអនុលោមតាមមាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ថិរវេលាចំនួន ១៥ ថ្ងៃ ដែលត្រូវដាក់ចម្លើយតបរួម គឺចាប់រាប់ពីពេលជូនដំណឹងអំពីការដាក់ឯកសារបកប្រែជាភាសាខ្មែរទាំងអស់នៃសារណាទាំងឡាយដែលត្រូវបានដាក់។

ភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**
**Co-juge d'instruction International**